[*អ្នកសម្ភាសៈ សាយ តុលា- អ្នកផ្តល់បទសម្ភាសន៍ៈ ជី មុនីវង់*]
[*Interviewer: Tola Say*. Interviewee: Chi Monivong]

[00:00]

ខ្ញុំបាទឈ្មោះ ជី មុនីវង់ ភេទប្រុស និង ខ្ញុំមានអាយុ៣០ឆ្នាំនៅក្នុងឆ្នាំថ្មីនេះ។ ទីលំនៅរបស់ខ្ញុំបច្ចុប្បន្ន គឺស្ថិតនៅភូមិ ស្រះស្រង់ខាងជើង សង្កាត់អង្គរធំ ក្រុងសៀមរាប និងខេត្តសៀមរាប។ សព្វថ្ងៃនេះ ខ្ញុំមានប្រពន្ធរួចហើយ។ ហើយខ្ញុំមានកូនចំនួនពីរនាក់។
My name is Chi Monivong, male; and I am 30 years old. My current address is located in north Sras Srang village, Sangkat Angkor Thom, Krong Siem Reap and Siem Reap province. I am married. And I have two children.

ការងាររបស់ខ្ញុំសព្វថ្ងៃ ខ្ញុំជាមន្ត្រីបរិស្ថាន ក្នុងតំបន់ការពារទេសចរណ៍អង្គរ។ ការិយាល័យខ្ញុំស្ថិតនៅទល់មុខកន្លែងលក់សំបុត្រចាស់។
I am an officer in the Environment Department of Angkor Tourism. My office is situated in front of a previous ticket selling place.

ខ្ញុំមានតែប៉ុណ្ណឹង។
I have only this [to say].

[00:33]

*តើបងធ្វើការនៅទីនោះបានប៉ុន្មានឆ្នាំហើយ?*
*How long have you been working there?*

ខ្ញុំបានធ្វើការនៅទីនោះបានរយៈពេលប្រាំឆ្នាំហើយ។ [និយាយម្តងទៀតៈ ខ្ញុំបានធ្វើការនៅទីនោះបានរយៈពេលប្រាំឆ្នាំហើយ។]
I have been working there for five years now. *[Repeats answer]* I have been working there for five years now.

*បងកំពុងកាន់អង្គួចពេលនេះ។ តើបងចេះធ្វើអង្គួចដែរឬទេ?*
*You are holding an Angkuoch in your hand. Do you know how to make Angkuoch?*

ខ្ញុំកំពុងកាន់អង្គួច ហើយខ្ញុំក៏ចេះធ្វើអង្គួចដែរ។ ខ្ញុំចេះធ្វើ ហើយខ្ញុំបានធ្វើបានបួនឬប្រាំឆ្នាំដែរ។ តែនៅពេលដែលខ្ញុំធ្វើការពេញម៉ោង ខ្ញុំមិនសូវមានពេលធ្វើដូចកាលនៅផ្ទះទៀតទេ។ ខ្ញុំមិនបាននៅផ្ទះទេ។ តែនៅពេលដែលបងស្រីចង់ដឹងអំពីការធ្វើអង្គួច ខ្ញុំក៏ធ្វើ និងរៀបរាប់ប្រាប់។
I am holding Angkuoch and I also know the Angkuoch making process. I know how to make Angkuoch and I made them for four or five years. When I got my full time job, however, I did not have time to do so, as I no longer had free time to be at home. I do not have a lot of time to stay home now. But when you wanted to witness the Angkuoch making process, I decided to do this and show you.

[01:09]

*តើបងរៀនធ្វើអង្គួចតាំងពីពេលណា?*
*When did you learn to make Angkuoch?*

ខ្ញុំបានរៀន... ខ្ញុំមិនបានចាំឆ្នាំដែរ។ បើគិតមើលទៅ ខ្ញុំធ្វើតាំងពីខ្ញុំអាយុ២៤ឆ្នាំ។ ហើយឥឡូវនេះ ខ្ញុំអាយុ៣០ឆ្នាំហើយ។ វាច្រើនដែរ។

I learned... I do not remember in what year. I think I learned to make this instrument when I was 24 years old. Now I am 30 years old now. It has been many years.

ខ្ញុំបានឈប់ធ្វើអង្កួច...ខ្ញុំធ្វើអង្កួចបានរយៈពេលបួនឆ្នាំ។ ពេលដែលខ្ញុំមានការងារធ្វើ ខ្ញុំមិនសូវមានពេលធ្វើអង្កួចទៀតទេ។ ខ្ញុំមិនបានធ្វើ។ ពេលដែលពុកទំនេរ គាត់តែងតែធ្វើជាមួយចៅគាត់ចំនួនពីរនាក់។ ពួកគេចេះធ្វើអង្កួចនេះដែរ។
I stopped making Angkuoch. I stopped making it four years ago now. When I got my full time job, I did not have time to do it. I could not do it. When my father is free, he always makes Angkuoch with his two grandsons. They know how to make Angkuoch too.

[01:48]

*តើបងរៀនធ្វើអង្កួចតាំងពីបងនៅជាសិស្ស?*
*Did you learn to make Angkuoch when you were a student?*

កាលដែលខ្ញុំចាប់ផ្តើមធ្វើអង្កួចនោះ ខ្ញុំនៅរៀនដែរ។ ខ្ញុំរៀនថ្នាក់ទី១២។ ពេលដែលចេញមកពីរៀនវិញ ខ្ញុំទំនេរ។ ហើយខ្ញុំក៏ធ្វើបួនដប់សម្រាប់លក់ឱ្យគេ។ ខ្ញុំទទួលបាន២០០០០ រៀលក្នុងអង្កួចចំនួន២០។ កាលនោះ បងខ្ញុំឱ្យ។ ខ្ញុំទុកវាគ្រាន់សម្រាប់ទៅរៀន។
When I started to make Angkuoch, I was studying too. I learned to make it when I was in grade 12. When I came home from school, I had free time. Then I started to make a dozen Angkuoch for selling. I earned 20, 000 Riel [c. USD5] by selling 20 Angkuoch. At that time, my brother nominated that price and would buy them from me [to on-sell]. I kept that money for my study.

[02:13]

*តើបងចេះធ្វើអង្កួចប្រភេទអ្វី?*
*What type of Angkuoch did you make?*

អង្កួចនេះធ្វើពីឫស្សី។ ទាល់តែឫស្សីលោក ឬឫស្សីព្រៃទើបអាចធ្វើបាន។ បើខ្ញុំប្រើឫស្សីបំពង់ វានឹងមិនលឺសម្លេងទេ ដោយសារវាជាប្រភេទឫស្សីសាច់ស្តើង។ វាទន់។
That type of Angkuoch was made from bamboo. It could be made from local or wild bamboo. If I used another type of bamboo [like that used to make palm juice containers], it would not work because that [bamboo] is thin and soft.

[02:34]

*ហេតុអ្វីបានជាពេលនោះបងចង់ចេះធ្វើអង្កួច?*
*Why did you want to make Angkuoch at that time?*

កាលនោះ ខ្ញុំទៅរៀន។ ខ្ញុំគ្មានការងារអ្វីធ្វើទេ។ ដូច្នេះ ខ្ញុំទំនេរនៅផ្ទះ។ ពេលដែលពុកខ្ញុំធ្វើ ខ្ញុំក៏ចាប់ធ្វើដែរ។ ពុកខ្ញុំប្រាប់ថា បើខ្ញុំធ្វើអង្កួច ខ្ញុំអាចលក់បានលុយ ១០០០រៀល ទៅ ២០០០រៀល។ ខ្ញុំធ្វើតាមគាត់។ ខ្ញុំអាចធ្វើមួយក្នុងមួយថ្ងៃបានបួនដប់ ខ្ញុំអាចបានលុយទៅរៀន។ [សើច...]
At that time, I was studying. I did not have any work. So I was free at home. When my father made Angkuoch, I started to copy him. My father told me that if I make Angkuoch, I could earn 1000 Riel to 2000 Riel per piece. I obeyed him. I could make a dozen Angkuoch and I could support my study. [Laughs...]

[02:55]

*ពេលនោះ តើអ្នកណាជួយលក់អង្កួចឱ្យបង? តើបងទៅលក់ដោយខ្លួនឯង?*
*Who helped you to sell your Angkuoch? Did you go to sell them by yourself?*

> បងប្រុសខ្ញុំបង្កើតជាអ្នកលក់នៅក្នុងប្រាសាទតាព្រហ្ម។ ចួនកាល គាត់ជាអ្នកយកទៅ។ ចួនកាល មានអ្នកដទៃមកយកទៅលក់ដែរ។ គេកុម្មង់ ១០ ២០ ឬ៣០។ គេកុម្មង់តាមតិចឬច្រើនតាមការលក់។ បើគេលក់ដាច់ច្រើន គេកុម្មង់ច្រើន។ តែបងប្រុសខ្ញុំ គាត់មកយកជាប្រចាំ។ ចួនកាល ២០ ជួនកាល១០។ ឱ្យតែមាន គាត់យកវាទៅលក់។ ភាគច្រើន ខ្ញុំលក់ឱ្យបងប្រុសខ្ញុំ។
> My brother was a seller at Ta Prohm temple. Sometimes he took them to sell. Sometimes, there were other buyers who wanted to [on-]sell them. They took 10, 20 or 30 [from me to on-sell]. They ordered more or less depending on their sales. If they could sell well, they ordered many. However, my brother took orders regularly [from me]. Sometimes he took 20 or 10. Whenever I had them, he took them [to sell]. Most of the time, I sold them to my brother.

[03:33]

*តើបងចេះធ្វើអង្កួចមកពីណា?*
*Who did you learn how to make Angkuoch from?*

> ខ្ញុំចេះធ្វើអង្កួចនេះមកពីឪពុករបស់ខ្ញុំ។ ឪពុកខ្ញុំធ្វើពេលទំនេរ។ កាលនោះយូរហើយ! ពេលនេះ គាត់ចាស់ហើយ។ ពេលដែលគាត់ទំនេរ ហើយគាត់មិនមានអ្វីធ្វើ គាត់ធ្វើអង្កួចលក់ដើម្បីជីវភាព។ គាត់ធ្វើសម្រាប់លក់។ ពេលដែលគាត់ធ្វើ ហើយគាត់ឃើញខ្ញុំទំនេរ គាត់ក៏ឱ្យខ្ញុំរៀនធ្វើដែរ។ អញ្ចឹងហើយ ខ្ញុំក៏ចេះធ្វើរហូតមកដល់ឥឡូវ។
> I learned how to make Angkuoch from my father. My father made them when he had free time. That was a long time ago. But now, he is getting old. When he was free, he did not have things to do. So then he made Angkuoch to generate income. He made them to sell. When he did that and he saw me free, he told me to do it too. That is why I still know how to make Angkuoch .

[04:00]

*អប្បាញ់មិញ បងប្រាប់ថាបងចេះធ្វើអង្កួចតាំងពីប្រាំមួយឆ្នាំមុន! ដូច្នេះ ខ្ញុំចង់ដឹងថា តើពេលនោះបងធ្វើរាល់ថ្ងៃ?  ឬមួយអាទិត្យម្តង? ឬយ៉ាងណា?*
*Just now, you said that you learned to make Angkuoch six years ago. So I would like to know whether you made it every day? Once a week? Or something else?*

> តាំងពីពេលចាប់ផ្តើម ខ្ញុំធ្វើវារាល់ថ្ងៃ។ ខ្ញុំធ្វើរាល់ថ្ងៃ។ ក្នុងមួយថ្ងៃ ខ្ញុំធ្វើ ១០ ឬ១៥។ បើថ្ងៃណា ខ្ញុំមិនបានរៀន ខ្ញុំធ្វើតែមួយថ្ងៃ ឬកន្លះថ្ងៃ។ ខ្ញុំអាចធ្វើបានច្រើន។ ជួនកាល ខ្ញុំអាចធ្វើបាន២០,  ១៥ ឬ២៥។ ពេលដែលមិនបានទៅរៀន ខ្ញុំនៅផ្ទះ។ បើមានពេលច្រើន ខ្ញុំធ្វើបានច្រើន។ បើមានពេលតិច ខ្ញុំធ្វើបានតិច។
> When I started making Angkuoch, I did it every day. I did it every day. I could make 10 to 15 per day. On the days when I did not go to school, I spent time to make them all day long, or half of a day. I could make a lot. Sometimes I could make 20, 15 or 25. When I had no classes, I stayed at home. If I had a lot of time, I could do more. If I had less time, I could do less.

[04:49]

*បើជារួម បងធ្វើបានប៉ុន្មានឆ្នាំហើយ?*
*How long have you made Angkuoch?*

ដូចខ្ញុំបាននិយាយ ខ្ញុំបានធ្វើវាចំនួនបួនឆ្នាំហើយ។ ប្រហែលបួន ឬបីឆ្នាំ។ ខ្ញុំមិនបានចាំដែរ។ តាំងតែពីពេលដែលខ្ញុំចូលធ្វើការ ខ្ញុំឈប់។ តាំងតែពីពេលដែលខ្ញុំចូលធ្វើការ ខ្ញុំអត់មានពេល ដោយសារតែការងារខ្ញុំរវល់ដែរ។ ឥឡូវ គេមិនចង់ទិញទៀតទេ។ ខ្ញុំមិនដឹងដែរ។ អ្នកលក់ថា គេលក់មិនដាច់។ ខ្ញុំមិនដឹងដែរ ដោយសាររបស់នេះសល់ពីយូរលង់មកហើយ។
As I told you, I have not made Angkuoch for four years now. Around four or three years. I do not remember. I stopped when I got a full-time job. Since I got a job, I have not had time because I am very occupied with my work. Now, people do not want to buy [Angkuoch]. I do not understand why. The sellers told me that they could not sell them well. I have no idea why, yet this instrument has been left to us from our ancestors.

[05:25]

*ក្រៅពីធ្វើឧបករណ៍អង្គួច តើបងចេះធ្វើឧបករណ៍ដទៃទៀតទេ?*
*Besides making Angkuoch, do you make other instruments too?*

ខ្ញុំធ្វើអ្វីទៀតទេ? ខ្ញុំធ្វើតែប៉ុណ្ណឹង។ តែអង្គួចមួយមុខ។ ពេលមុន ខ្ញុំធ្វើវា។ តែដល់ពេលខ្ញុំឈប់ ខ្ញុំឈប់ធ្វើវារហូតដល់សព្វថ្ងៃ។
What other instruments do I make? I make only that instrument. Only Angkuoch! Before, I made it. But now I have stopped and I have stopped until now.

[05:42]

*តើបងចាប់ផ្តើមលេងអង្គួច ពេលដែលបងចាប់ផ្តើមធ្វើវា?*
*When you started to play it, did you also start to make it?*

ពេលដែលខ្ញុំចាប់ផ្តើមធ្វើអង្គួច ខ្ញុំក៏ចាប់ផ្តើមផ្ទាត់វាដែរ។ មុនដំបូង ខ្ញុំផ្ទាត់មិនលឺទេ។ តែនៅពេលដែលបងប្រុសខ្ញុំប្រាប់ណពីរបៀបនៃការផ្ទាត់ ខ្ញុំអាចផ្ទាត់លឺធម្មតា។ បើខ្ញុំធ្វើវា ហើយវាផ្ទាត់មិនលឺ ការលេងក៏មិនអាចលឺដែរ។ វាប៉ុណ្ណឹង!
When I started to make Angkuoch, I started to ‘flick’. At first, I could not play correctly. But when my brother told me a playing technique, I could play it. If I made it and it could not produce any sound, it would make no sound either in the real playing. That’s it.

ការលេងរបស់វាមានភ្លេងអ្វីក៏ខ្ញុំមិនចេះដែរ។ ខ្ញុំដឹងត្រឹមតែផ្ទាត់យ៉ាងណាឱ្យវាលឺ។
I could not make any rhythm with Angkuoch. I could only make it produce a sound.

ចេះតែផ្ទាត់ឱ្យលឺបែបនេះ! [បង្ហាញ]
Produce a sound like this! [Demonstrates]

ខ្ញុំចេះតែប៉ុណ្ណេះ។ ខ្ញុំមិនចេះដាក់ភ្លេងអ្វីទេ។ [សើច...]
I know only this. I cannot make any rhythm. [Laughs...]

[06:18]

*តាំងតែពីបងចេះលេងមក តើបងនៅតែបន្តផ្ទាត់លេងមករហូត?*

*Since you know how to play, have you kept playing until now?*

ខ្ញុំចេះផ្ទាត់លេងតែប៉ុណ្ណេះ។ [សើច...] ខ្ញុំមិនដឹងធ្វើយ៉ាងម៉េច។
I play it for fun only. [Laughs...] I do not know.

ខ្ញុំចេះផ្ទាត់លេងតែប៉ុណ្ណឹង។ [សើច...]
I just play it for fun. [Laughs...]

*ជាទូទៅ តើបងលេងម្តងប៉ុន្មាននាទី?*
*How many minutes do you normally play for?*

ខ្ញុំផ្ទាត់តែមួយភ្លែតៗពេលដែលខ្ញុំធ្វើ។ ឧទាហរណ៍ ពេលដែលខ្ញុំធ្វើ ខ្ញុំចិតករវា រួចខ្ញុំផ្ទាត់...
I play for a few seconds as I'm making it. For example, when I carve, when I carve its neck then I play. [Demonstrates]

ខ្ញុំផ្ទាត់តែប៉ុណ្ណឹង។ បើសិនជាវាលឺ ខ្ញុំឈប់ផ្ទាត់ទៅ។ បើសិនជាវាមិនលឺ ខ្ញុំនឹងចិតបន្ថែមទៀត ដើម្បីឱ្យវាមានសម្លេងលឺខ្លាំង។ ប៉ុណ្ណឹង!
I play like this. If it produces a sound, I stop playing. If it does not produce a sound, I will carve it more to make it produce a louder sound. That's it.

*ក្រៅពីចេះលេងអង្កួច  តើបងចេះលេងឧបករណ៍អ្វីផ្សេងទៀតទេ?*
*Besides Angkuoch, do you play other instruments?*

អត់ទេ! ខ្ញុំចេះតែប៉ុណ្ណឹង។ ខ្ញុំមិនចេះលេងឧបករណ៍អ្វីផ្សេងទៀតទេ។
No! I only know this one. I do not play other instruments.

*អត់ចេះលេងទេ?*
*You don't know any others?*

បាទ! មិនចេះទេ!
That's right, I don't.

ខ្ញុំចេះផ្ទាត់អង្កួចនេះដោយសារខ្ញុំជាអ្នកធ្វើ។ បើខ្ញុំមិនចេះ វាមិនកើត។ ដូច្នេះ ខ្ញុំត្រូវរៀនផ្ទាត់វាឱ្យលឺ។ តែបើធ្វើជាសម្លេងចង្វាក់ ខ្ញុំមិនចេះ។ ខ្ញុំត្រូវរៀនផ្ទាត់វាឱ្យលឺ ហើយគេថាពិរោះ។ [សើច...]
I know how to play Angkuoch because I used to make them. It would not be possible to make them if I did not know the playing. So I had to learn to play. But if you wanted me to make a rhythm through my Angkuoch playing, I do not know how. When I produce a good sound from the Angkuoch, people say that it is nice. [Laughs...]

[07:09]

*តើបងចូលចិត្តផ្ទាត់នៅពេលណា?*
*When do you like to play?*

ចូលចិត្តផ្ទាត់? ពេលដែលខ្ញុំធ្វើ ខ្ញុំត្រូវការផ្ទាត់។ ចួនកាល ខ្ញុំផ្ទាត់ពេលដែលខ្ញុំធ្វើរួច។ ចួនកាល ខ្ញុំផ្ទាត់នៅពេលដែលមានភ្ញៀវមកញ៉ាំបាយផ្ទះម្តាយខ្ញុំ។ ចួនកាល ខ្ញុំលក់ដាច់។ ចួនកាល ខ្ញុំលក់មិនដាច់។
Like to play? When I made them, I had to play. Sometimes I played when I finished the making process. Sometimes I played when there were customers

who came to eat food at my mother’s house. Sometimes, I could sell well. Sometimes, no one bought them.

*លក់ដោយខ្លួនឯងយ៉ាងម៉េច?*
*How is that?*

ពេលដែលមានភ្ញៀវ ខ្ញុំកាន់យកទៅលក់។ ហើយខ្ញុំផ្ទាត់ឱ្យពួកគេស្តាប់។ ពេលដែលគាត់សួរថា៖ នេះជារបស់អ្វី។ ខ្ញុំប្រាប់ថា៖ វាជាអង្គួច។ បើគាត់ចង់ដឹង និងចង់បាន គាត់នឹងសួរពីរបៀបផ្លុំ។
When there were customers at home, I took the Angkuoch to sell. Then, I played for them. When they asked, ‘What is this?’. I told them that it is ‘Angkuoch’. If they wanted to know more and buy it, they would ask me about the playing technique.

*តាំងពីបងចេះធ្វើអង្គួច តើបងធ្លាប់បង្រៀនអ្នកផ្សេងដែរឬទេ?*
*Since you make Angkuoch, have you ever taught anyone else to make them?*

បង្រៀនអ្នកផ្សេងឱ្យចេះធ្វើអង្គួចដែរ?
Taught other people to make Angkuoch?

*ចាស!*
*Yes!*

ខ្ញុំមិនដែលបានបង្រៀនទេ តែឪពុកខ្ញុំបង្រៀនចៅរបស់គាត់។ តែចំពោះខ្ញុំ ខ្ញុំមិនបានបង្រៀនទេ ដោយសារខ្ញុំមិនមានពេលដែរ។ ខ្ញុំរវល់ការងារដែរ។ បើក្មួយរបស់ខ្ញុំ ពួកគេរៀនចេះពីជីតា។ តាជាអ្នកបង្រៀន។ ពេលថ្ងៃសៅរ៍ ឬអាទិត្យ ពួកគេមិនទៅរៀន គាត់បង្រៀនពួកគេឱ្យធ្វើ។ពេលដែលធ្វើបាន បងប្រុសខ្ញុំជាអ្នកទិញ។
I have never taught anyone. However, my father taught his grandsons. For me, I could not teach because I do not have time. I am also busy with my work. My nephews learned to make Angkuoch from their grandpa.

តែពេលនេះ ពួកគេដូចជាមិនធ្វើទេ ដោយសារពួកគេជាប់រវល់រៀន។ ពេលដែលពួកគេរៀនដល់ថ្នាក់ទី ៨ ឬទី៩  ពួកគេមិនមានពេលមកធ្វើទេ ដោយសារពួកគេរវល់ទៅរៀន។ ហើយពុកខ្ញុំ និងខ្ញុំក៏រវល់ការងារដែរ។ ដូច្នេះហើយ ពួកយើងមិនសូវធ្វើ។ ហើយអ្នកទិញក៏មិនសូវមានដែរ។ បងប្រុសខ្ញុំ គឺរវល់ធ្វើការ ដូច្នេះក៏គ្មានអ្នកទិញ។ អ្នកខ្លះក៏មិនសូវមករកទិញដែរ។
But now they have stopped making it already because they have been busy with their studies. When they reached Grade 8 or 9 [at school], they did not have time to come because they needed to study. At the same time, my father is also busy with his work. That is why we do not make it now. And there are not many buyers either. My brother is busy with his work and so no one could come to buy them from us. No one comes to buy them from us.

[08:43]

*តើបងគិតថា ការលេង និងការធ្វើអង្គួចនេះពិបាកដែរឬទេ?*
*Is the Angkuoch playing and making hard for you?*

ចំពោះខ្ញុំ ពេលដែលខ្ញុំចេះធ្វើបែបនេះហើយ ខ្ញុំគិតថាវាមិនពិបាកទៀតទេ។ ចំពោះអ្នកដែលមិនចេះ ពួកគេគិតថាពិបាក ដោយសារវាត្រូវការការដាប់ ការដាក់អណ្តាត  ហើយត្រូវចិតឬស្សីឱ្យតូចៗ។ ដូច្នេះ វាពិបាកក្នុងការធ្វើ។

For me, once I knew the making process, I thought it was no longer hard. For those who do not know, they think it is hard because, in the process, it’s necessary to make a hole, put on the lamella and carve the bamboo into small pieces. So it seems hard to make.

ចំពោះការផ្លុំ អ្នកខ្លះមិនអាចផ្លុំលឺទេ។ អ្នកមិនចេះផ្ទាត់ ពួកគេមិនអាចផ្ទាត់លឺទេ។ គេមិនហៅថា «ការផ្លុំ» ទេ គេហៅវាថា «ការផ្ទាត់»។ ទាល់តែខ្លុយទើបគេហៅ «ផ្លុំ»។ គេហៅវាថា «ផ្ទាត់»។ អ្នកមិនចេះផ្ទាត់ ពួកគេមិនអាចផ្ទាត់លឺទេ។
For the blowing, some people cannot produce a sound from the Angkuoch. If they do not know the technique, they cannot play. We do not call it ‘blowing’, we call it ‘playing’. We say ‘blowing’ for khloy [Khmer flute]. We say ‘playing’ for this instrument. For those who do not know the technique, they cannot produce any sound.

[09:14]

*[សាកល្បងលេង]*
*[Tests playing]*

ប៉ះធ្មេញ! ចួនកាល វាមិនលឺទេ ដោយសារវាជាប់នឹងអណ្តាត។ ខ្ញុំត្រូវការរៀនផ្ទាត់ដែរ។ វាមិនពិបាកពេកទេ។ វាចំណាយពេលយ៉ាងច្រើន ១០ទៅ២០នាទី។
It is hitting my teeth. Sometimes it does not produce any sound because it sticks to my tongue. I have had to learn too. It is not very difficult. It takes 10 to 20 minutes maximum.

ខ្ញុំត្រូវដាក់គៀបបែបនេះ។
I have to hold it like this.

*[សាកល្បងលេងឧបករណ៍]*
*[Tests the instrument]*

ខ្ញុំត្រូវបញ្ចេញខ្យល់តិចៗ និងផ្ទាត់ ដូច្នេះវានឹងបញ្ចេញសម្លេង។
I have to release a soft breath and play so then it can produce a good sound.

*ទម្រាំតែបងចេះធ្វើ តើបងត្រូវចំណាយពេលយូរប៉ុណ្ណា?*
*How long did it take you to learn the making process?*

បើខ្ញុំកាត់ឫស្សីរួចស្រេច និងមានកំណាត់ឫស្សីអារទុករបៀបនេះ និងយកមកពុះ ខ្ញុំអាចចំណាយពេលពី១៥នាទី ឬដប់នាទីក្នុងការធ្វើអង្គួចមួយ។ វាក៏អាស្រ័យនឹងការធ្វើលឿន ឬយឺតផងដែរ និងកាំបិតមុតដែរឬអត់។ វាអាស្រ័យលើអ្នកធ្វើ។ ដូច្នេះ ខ្ញុំអាចនិយាយបានថា ខ្ញុំចំណាយពេល១៥នាទីដើម្បីធ្វើអង្គួចមួយ។ រយៈពេល១៥នាទី
If I already have the bamboo in small pieces like this, I can chop them. [Then] I spend around 15 minutes or 10 minutes to make one Angkuoch. It depends on the making process and the knife. And it depends on the maker too. So I can say I spend 15 minutes to make one Angkuoch. 15 minutes!

[10:19 - END]